# នៅមុខខ្លោងទ្វាររោងចក្រ

ឈុតទី 5/6




អង្គការ
ពលកម្ម
អន្តរជាតិ

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា


ឆាប់ឡើងម៉ោស៊ីណា... យើងខ្លួនរាងយឺតបន្តិចហើយ ទៀតក៏....!
ទៅហើយៗ....
ខ្ញុំរវល់ទៅខ្ចប់កាដូឱ្យស្រីភីក្រុមផ្តិច ហើយនិងមើលក្រែងលោមានភ្លេច សម្ភារសំខាន់អីក្លឹងណា...
សម្បើមជាពេលប្រជុំសហជីពលើកក្រោយនេះ ស៊ីណាឯងមិន ម៉ោយឺតពេលទៀតទេបើមិនអញ្ចឹង ខ្ញុំមិនដឹងត្រូវនិយាយប្រាប់ សមាជិកយើងយ៉ាងម៉េចទេ.......អូ...ប្រាប់គេថាអនុប្រធាន ថ្មីជំនាញខាងម៉ោយឺតទៅម៉េចដែរហ្អស់?
ជាភ័! កុំនិយាយបន្ទោសខ្ញុំមើល ..... ខ្ញុំកំពុងតែបុកពោះស្រាប់ផង.... ....វ១ ខ្ញុំ និយាយខុស រឺក៏ភ្លេចពាក្យដែលខ្ញុំត្រៀម និយាយទៅ...
មិនបាច់ភ័យទេស៊ីណា.....ចាំពេលទៅដល់ ស៊ីណាឯង សាកសមនិយាយជាមួយអ្នកផ្ទះខ្ញុំទៅខ្ញុំជឿថា គ្រប់គ្នា ប្រាកដជានឹងអង្គុយស្តាប់ស៊ីណាឯង ទៀងចំហរមាត់មិន ខាន....
តោះពួក យើងទៅ....!


៎ ហូស៊ីដេ ហូស៊ីដេះ ជាថ្ងៃធ្វើបុណ្យ៎
កូនស្រី! .....កូនស្រី..... ម៉ោឱ្យលឿន ឡើងកូន ....កូនឯង !
វ៉ា.....!!!
វ៉ា.....!!!
យ៉ាងម៉េចហ្នឹង.... មានរឿងអីអ៊ែម៉ែ?
គឺស្រីភ័ក្ត្រហ្នឹងណា....វាឈឺទៀតហើយ.....មើលចុះ វាចុះខ្សោយ ខ្លាំងណាស់..... ម៉ែព្រួយចិត្តផងហើយទៀតក៏....ជិត២ថ្ងៃហើយ វាអត់ សូវទៅសោះ....
ស៊ីណា.... មានរឿង មិនស្រួលហើយ.....
សមហើយ ដែលវាចេះតែឈឺអញ្ចឹងនោះ ! មើលតែរបស់ ដែលកូនឯងឱ្យវាបៅចុះ .....មានតែម្សៅហើយនិងទឹកឱ្យគ្រប់ .....កាលពីដើម គេមានតែទឹកដោះម្ដាយ តែប៉ុណ្ណោះ!


យាយ....យាយកុំខឹងស្រីពៅអី....គ្នាត្រូវទៅធ្វើការ គ្នាគ្មានជំរើសអីផ្សេងក្រៅពីនេះទេ....ស្រីពៅមិនអាចទៅផ្ទះរហូតបានទេ ហើយសម័យនេះអ្នកណាក៏គេប្រើទឹកដោះគោម្សៅដែរ ក្មេងមិនមែនឈឺមកពីបញ្ហាហ្នឹងទេយាយ.....
ពួកក្មេងៗអស់ឯងឥឡូវនេះចេះតែមាត់ឱ្យប៉ប៉ាច់ គ្មាននរណាស្ដាប់ចាស់ទេ.... ពួកឯងស្មានថាយើងនេះគ្មានដឹងខ្យល់អីអ៊ំ?
ខ្ញុំដឹងថាយាយនិយាយត្រូវហើយ.... បើខ្ញុំអាចនៅផ្ទះបាន ខ្ញុំប្រាកដជានៅមិនខាន...តែបើខ្ញុំមិនទៅធ្វើការ បាននរណារកលុយចិញ្ចឹមកូនខ្ញុំ? ហើយបើយើងគ្មានលុយ ចុះពេលស្រីក្រូវឈឺ យើងបានលុយពីណាទៅឱ្យពេទ្យ?
ប្រសិនបើឯងបំបៅដោះ វាជំនួសអាហារបស់ហ្នឹង...ប្រហែលជាឯងមិនមែនចេះតែបង្ខិតរត់រកពេទ្យៗអញ្ចឹងទេ!
យាយមិនយល់ទេ....ជីវិតឥឡូវខុសពីមុន ពួកខ្ញុំមានការទទួលខុសត្រូវច្រើន ហើយម្នាក់ៗត្រូវតែធ្វើការដើម្បីរកលុយ ស្រីពៅឈប់សំរាកមាតុភាពបានតែពីរខែទេ ហើយសំរាប់រយៈពេលនេះ ខាងរោងចក្រគេបើកលុយឱ្យ ប៉ុន្តែគេមិនអាចចិញ្ចឹមយើងរហូតបានទេ....
ខ្ញុំដូចជាវិលវល់អស់ហើយបង....តែយាយប្រហែលជានិយាយត្រូវ ព្រោះអីចាប់តាំងពីខ្ញុំឈប់បំបៅដោះស្រីក្រូ ហើយឱ្យវាបៅម្សៅទឹកដោះគោជំនួសវិញ វាចេះតែឈឺរហូត....។ ឥឡូវនេះ លុយដែលខ្ញុំរកបានមកគឺសំរាប់តែចំណាយទៅលើម្សៅទឹកដោះគោនិង បង់ថ្លៃពេទ្យតែប៉ុណ្ណោះ.....
អញ្ចឹង ស្រីពៅឯងគួរតែគិតពីកាត់បន្ថយម៉ោងធ្វើការខ្លះទៅ
ខ្ញុំដឹងថាបងនិយាយនេះចង់ឱ្យខ្ញុំល្អ ប៉ុន្តែពេលដែលខ្ញុំឈប់សំរាកមាតុភាពនេះ លុយប្រាក់ខែខ្ញុំ គេឱ្យតែពាក់កណ្ដាលប៉ុណ្ណោះ...ឡាប់តែឯងម៉ោងជាអញ្ចឹងហើយឥឡូវនេះខ្ញុំត្រូវតែត្រលប់ទៅធ្វើការដើម្បីឱ្យបានប្រាក់ខែពេញវិញ....រឿងគឺវាតែប៉ុណ្ណឹងហ្នឹងបង !


ស៊ុណាឯងមិនមែនជាម្ដាយគេ ស៊ុណាឯងមិនយល់ទេ....សព្វថ្ងៃនេះតើមាន អ្នកណាគេអាចអង្គុយនៅផ្ទះបំបៅដោះកូនម៉ោងហើយរាល់ល្ងាចកើតទៅ? អញ្ចឹង ហើយបានជាគេបង្កើតឱ្យមានជាម្សៅទឹកដោះគោដើម្បីជំនួសទឹកដោះ ម្ដាយហ្នឹងណា !
ជាវាឯងនិយាយ ឱ្យចេះគិតផងមើល៍! តើទឹក ដែលផងចេញពីអណ្ដូងនៅទីនេះ វាស្អាតប៉ុណ្ណាទៅ?
...តើទឹកហ្នឹងជានិច្ចជាកាល តែងតែយកទៅដាំឱ្យពុះ ហើយទុកវា ឱ្យត្រជាក់ទៅវិញនៅត្រឹមសីតុណ្ហភាព ដែលគេបានកំណត់ត្រឹមត្រូវដែរទេ?
បានហើយៗ ស៊ុណា...ឱ្យខ្ញុំសុំទោសចុះ.... ប៉ុន្តែយើងទាំងពីរនាក់សុទ្ធតែដឹងច្បាស់ហើយ ថា បន្ទាប់ពីរយៈពេល ៣ខែ ស្រីពៅត្រូវតែ ត្រលប់ទៅធ្វើការវិញ ព្រោះការឈប់សំរាក មាតុភាពរបស់នាងត្រូវចប់ត្រឹមនេះ
ស្រីពៅចុះម៉េចក៏មិនយកស្រីភ័ក្រ្តទៅ រោងចក្រទៅ ធ្វើដូចនេះកូនអាចបំបៅ បានណា ។
រឿងនេះខ្ញុំដូចមិនដែលលឺគេ និយាយផង...បែបគេមិនឱ្យ យើងយកទៅទេដឹង...?
ម៉ែស្រីនាងធ្លាប់ប្រាប់ម៉ែថា រោងចក្រ កូនគាត់ឱ្យយកកូនមកបំបៅម៉ាថ្ងៃ ពីរ ដង....ហើយមិនមែនឱ្យបៅទឹកដោះ គោនោះទេ - គឺឱ្យបំបៅដោះតែម្ដង!
ពិតមែនឬម៉ែ? នេះជាអ្វីដែល ខ្ញុំចង់បានខ្លាំងណាស់....!
បញ្ហាគឺថា គេមិនទាន់បានឱ្យកន្លែងណាមួយ មកយើងដើម្បីយកមកធ្វើជាបន្ទប់បំបៅដោះ កូននៅឡើយនោះទេ ។


ប៉ុន្តែនេះគឺជាការងាររបស់យើងក្នុងនាមជាអ្នកតំណាងសហជីព ដើម្បីធ្វើយ៉ាងណាជំរុញឱ្យមានកន្លែងថែទាំកូននេះនៅក្នុងរោងចក្រយើង!
នៅក្លឹបប៊ុកប៊ីយ៉ា នារសៀលនោះ..................................
សូមផ្តល់ឱកាសនេះអោយខ្ញុំធ្វើជាថៅកែទៅ..... ម៉្យាងទៀតទឹកដោះគោរាល់កេះដែលខ្ញុំលក់បាន បងឯងនឹងផ្តល់កុំម៉ីស្យុងឱ្យខ្ញុំ២០% ដើម្បីឡើងទៀតមែនទេ?
ត្រូវហើយ.....ហើយបើគិតទៅក៏គ្មានការងារអីស្រួលជាងនេះទៀតដែរ ព្រោះឧបមាថាបើអត់ទាន់មានឱកាសលក់វិញ ឯងអាចដេកលេងសិនក៏បាន.....
....ហើយចុះបងលក់ឲ្យប៉ុន្មានទៅបងអេក ឲ្យបានចំណេញច្រើនបំផុតសម្រាប់ក្រុមហ៊ុនវិញគ្រប់?
ឯងជឿខ្ញុំទៅ.....ខ្ញុំរកបស់លក់ឱ្យគេស្ទើរតែមិនបានផង.... ខ្ញុំប្រាប់ឯងទៅចុះ ខ្ញុំអាចលក់ជាង៤សប់ផង់ទៅ ២៥០ រឺលែងតែបានពីសើកក៏ដែលខ្ញុំមាននៅក្នុងស្តុកទៀតផង....


នេះជាឡានរបស់បងឬ...?
ត្រូវហើយ.....វាគឺជាសំណព្វចិត្តខ្ញុំហើយ
មិប
ថ្ងៃបន្ទាប់ នៅក្នុងបន្ទប់ប្រជុំក្នុងរោងចក្រ..................
.....ច្បាប់ការងារបាន ចែងច្បាស់ណាស់.....
ម្ដាយទាំងអស់ ដែលកំពុងមានកូនតូច ត្រូវផ្ដល់ពេលវេលាមួយ១ម៉ោងក្នុងមួយថ្ងៃ ដើម្បីបំបៅកូន.... ហើយរយៈពេលនេះអាច វិភាគជាពីរបាន : គឺកន្លះម៉ោងនៅពេលព្រឹក និង កន្លះម៉ោងទៀតនៅពេលរសៀល...


បាទ...បាទ ត្រូវហើយលោក.....ប៉ុន្តែបើរោងចក្រផ្ដល់ជាម្សៅទឹកដោះគោហ្វរម៉ូឡា វី ក៏ឱ្យជាលុយទៅកម្មករដែលជាម្ដាយមានកូនតូចទាំងអស់នោះដើម្បីទិញម្សៅទឹកដោះវិញ ...ធ្វើដូច្នេះយើងមិនចាំបាច់ខាតពេលឱ្យពួកគេសំរាកបំបៅយ៉ាងនេះទេ ព្រោះវាធ្វើឱ្យតែផលិតភាពរបស់យើងធ្លាក់ចុះ មិនអញ្ចឹងអី?
ធ្វើអញ្ចឹងមិនបានទេ....បើនិយាយទៅតាមច្បាប់ ការដែលយើងផ្ដល់ជាលុយកាក់ វឺ ម្សៅទឹកដោះគោជំនួសឱ្យការសំរាកបំបៅដោះកូននេះគឺមិនត្រូវបានអនុញ្ញាតិទេ....
ម្យ៉ាងវិញកុសល្យ ឥឡូវនេះយើងកំពុងតែព្យាយាមលើកទឹកចិត្តម្ដាយ គ្រប់រូបអោយបន្តបំបៅដោះកូនព្រោះវាធ្វើឱ្យកូនមានសុខភាពកាន់តែល្អ និងចំណាយលុយកាក់អស់តិចទៀត
ត្រូវហើយ ក៏ប៉ុន្តែការនេះអាចធ្វើទៅបានលុះត្រាណាតែនាយនិយោជកផ្ដល់ជាកន្លែងណាមួយសមរម្យសំរាប់បុគ្គលិកដែលជាម្ដាយដើម្បីបំបៅដោះកូនដែរ ....គ្រប់រោងចក្រទាំងអស់ដែលមានបុគ្គលិកលើសពី១០០នាក់ ដូចជារោងចក្រកាត់ដេរសាមាគិកគាលោកនេះជាដើម ត្រូវតែរៀបចំបន្ទប់បំបៅដោះកូនមួយ ឱ្យដំណើរការ ជាពិសេសសំរាប់ពេលបំបៅនេះតែម្ដង ។
ថ្ងៃបន្ទាប់..............................
អេ៎...បងប្អូនស្រីៗមោស្ដាប់ខ្ញុំបន្តិច.... ក្នុងចំនោមអ្នកទាំងអស់គ្នានេះ មានអ្នកខ្លះមានកូនតូចរួចទៅហើយ .... ម្សៅទឹកដោះគោហ្វមុឡាវ័ន (Formula 1) វាគឺជាផលិតផលដែលល្អបំផុតនៅលើទីផ្សារ


ចុះពូកុសល្យ ទឹកដោះគោ ហ្នឹងថ្លៃអត់?
អាស្រ៊ីអា....ពួកយើងទាំងអស់គ្នាសុទ្ធតែដឹងច្បាស់ហើយ ថាកូនដែលកំពុងតែរីកចំរើនខាងក្នុងពោះរបស់ឯង វាមាន តំលៃប៉ុណ្ណា.... ដូច្នេះវាត្រូវការបំប៉នដោយម្សៅទឹកដោះ គោដែលល្អបំផុត គឺហ្វរមីឡា ទើបបាន ។
តែពូកុសល្យ៖ ខ្ញុំគ្មាន ផ្ទៃពោះអីទេណា៎!
អូ អញ្ចឹងតើ.... ប៉ុន្តែឥឡូវមិនទាន់មាន ថ្ងៃណាមួយគង់តែ មានទេ ហើយពេលនេះគឺជាពេលដែលត្រូវចាប់ផ្តើមគិតគូរពី អនាគតរបស់កូនៗអ្នកទាំងអស់គ្នាហើយ....ហើយគេអាច ទិញរបស់ខ្ញុំអស់ពីស្តុកផងក៏មិនដឹង....ដល់ពេលនោះ តើ មានអី សល់សំរាប់កូនអ្នកទាំងអស់គ្នាទៅ?
គឺនៅសល់ទឹកដោះម្តាយនោះអីពូកុសល្យ..... កូនតូចៗរបស់ពួកគេមានតែទឹកដោះម្តាយហ្នឹង ហើយ... អ្នកទាំងអស់គ្នានៅទីនេះភាគច្រើន សុទ្ធតែនៅក្មេង ហើយមិនទាន់មានផ្ទៃពោះ... សូម្បីតែប៉ុន្មានឆ្នាំទៀតក៏មិនទាន់ដឹងយ៉ាងម៉េច ផង ។
សុំណាអូ៎....ខ្ញុំរវល់ណាស់ គ្មានពេលទៅប្រកែកជាមួយនាងទេ.... ម្សៅទឹកដោះគោ ហ្វរមូឡាវ៉ាន់ (Formula 1) គឺជាជំនឿតែមួយគត់ សំរាប់អនាគតរបស់ពួកគេ...ទឹកដោះគោនេះងាយស្រួលរៀបចំខ្លាំង ណាស់ហើយគ្រាន់តែចាក់ទឹកលាយជាមួយម្សៅនេះទៅ វាជា ការស្រេចបាត់ទៅហើយ !
ប្អូនស្រី...សូមប្អូនគិតឱ្យបានវែងឆ្ងាយមុននឹងសំរេចចិត្តទិញរបស់ចំណែក នេះ.....អូនឯងគិតមើលទៅ តើអូនឯងមានលទ្ធភាព ប្រើម្សៅទឹក ដោះគោហ្នឹងដែរអត់? ទឹកដោះម្តាយ មិនចាំបាច់ត្រូវចំណាយលុយ កាក់អីទាំងអស់ ប្រសិនបើយើងមានសុខភាពល្អ និងហូបចុកបាន គ្រប់គ្រាន់ យើងអាចបំបៅដោះកូនបានច្រើនខែ....ច្រើនឆ្នាំ ប្រសើរ ជាងទឹកដោះគោហ្វរមីឡា ទៀតផង !


ស៊ីណា..ពួកយើងភាគច្រើនចេះតែចង់បំបៅដោះកូនហើយ តែក្នុងរោងចក្រយើងអត់មានបន្ទប់សំរាប់ឱ្យពួកយើងបំបៅដោះកូនផង... ដល់អញ្ចឹងយើងមានផ្លូវណាផ្សេងទៀត ក្រៅពីប្រើ ម្សៅទឹកដោះគោទៅ....?
បើកគ្រូពេទ្យគេស្គាល់អ្នកដែលធ្វើជាម៉ែគេទាំងអស់នេះ និយាយខ្លះទៅស៊ីណា...គេចេះតែដើរដោះខោអាវចោលកូនទៅទៀត? នាងមិនចាត់ទុកជាម៉ែគេ នាងមិនដឹងទេ !
បីសប្តាហ៍បន្ទាប់មក ក្នុងពិធីបុណ្យសពស្រីភ័ក្រ្ត នៅផ្ទះគ្រួសាររបស់ដារ៉ា.....
ញាតិមិត្ត បងប្អូនទាំងអស់សុទ្ធតែស្គាល់ប្អូនរបស់ខ្ញុំ ស្រីពៅនេះហើយ....អ្នកទាំងអស់គ្នាដឹងទេ...ដើម្បីស្រីភ័ក្រ្ត ប្អូនខ្ញុំហើយនិងប្តីបានខិតខំប្រឹងប្រែងខ្លាំងណាស់......ដោយសារតែខ្វះខាតលុយកាក់ នាងក៏ប្រញាប់ត្រលប់ទៅធ្វើការវិញ...សូម្បីតែខ្លួនខ្ញុំ ក៏បានជំរុញឱ្យនាងឆាប់ទៅធ្វើការវិញដែរ ព្រោះក្រុមគ្រួសាររបស់យើង សុទ្ធតែពឹងមកលើពួកយើង....ប៉ុន្តែពេលខ្លះ ការខំខ្លាំងពេកនេះ ធ្វើអោយយើងជួបនឹងផលវិបាកជាច្រើន ។
បង....រឿងនេះមិនមែនជាកំហុសអ្នកណាម្នាក់ទេ....បងកុំនិយាយអញ្ចឹងអី...
ប្អូនស្រី....បងនិយាយនេះគ្រាន់តែចង់ឱ្យអ្នកដទៃទៀតយល់ ហើយកុំឱ្យគេធ្វើខុសដូចយើងប៉ុណ្ណោះ....ខ្ញុំមិនមែនចង់ថា ការសំរេចចិត្តរបស់នាងវី ការសំរេចចិត្តរបស់ពួកយើងទាំងអស់គ្នាត្រូវ រឺខុសយ៉ាងណានោះទេ ប៉ុន្តែនៅក្នុងភូមិយើងនេះពិបាកណាស់ - ទឹកនៅក្នុងភូមិ មិនសូវស្អាត... ស្រីពៅមិនអាចស្ងោរសំលាប់ មេរោគពីដបទឹកដោះគោឱ្យបានស្អាត គ្រប់ពេលវេលាបាន.... ឥឡូវនេះទើបយើងដឹងថាជំងឺស្រីភ័ក្រ្ត គឺមកពីការដែលពួកយើងបំបៅកូនបែបនេះ....គឺដោយសារការខ្វះអនាម័យ ។




មួយសប្តាហ៍ក្រោយមក..................






បន្ទាប់ពីកម្មករចប់ម៉ោងការងារ កុសលបានរង់ចាំតាមការគ្រោងទុកជាមុន........




!!?
អាំសស.
បបូមមម!!!

**សេចក្តីថ្លែងអំណរគុណ**

សៀវភៅនេះត្រូវបានរៀបរៀង និង ផលិតដោយបុគ្គលិករបស់អង្គការ ILO ***គំរោងរោងចក្រកាត់ដេរប្រសើរ នៅកម្ពុជា*** លោក ខនង់ ប៊ុយ, លោក ជុំ ផល្លី, អ្នកស្រី ឌុ ការី, កញ្ញា ឈាង ធន្នី, អ្នកស្រី យស់ សុធា និង លោក វ៉ុន ពិស្សុ ។ អង្គការ ILO សូមថ្លែងអំណរគុណជាពិសេសចំពោះ លោក នីក វ៉ូដ (Navigator Communications) កញ្ញា ម៉ុម ផល្លីកា, លោក ម៉ៃ សុគន្ធ, លោក ឈិន ស៊ីណាត់, អ្នកនាង ស្វៃង សុជាតា, លោក ពៅ ពិសាន់, កញ្ញា រ៉ូនីដា លោក ផល់ សុភី និង កញ្ញា ពៅ ពេជ្រជរីនី (ជាអ្នកសំដែង ដែលត្រូវបានគេថតយកមកប្រើប្រាស់ក្នុងសៀវភៅ) សំរាប់ការចូលរួមវិភាគទានរបស់ពួកគេ ដើម្បីផលិតជាសៀវភៅ នេះឡើង ។

**វិចិត្រគំនូរដោយ**

លោក ហូសេ អែនស៊ីណា

Jose Encinas jose@tonle.net

**ឧបត្ថម្ភថវិកាដោយ**

សៀវភៅនេះត្រូវបានផលិតឡើងក្រោមការឧបត្ថម្ភថវិកា តាមរយៈកិច្ចព្រមព្រៀងរួមគ្នារវាង ទីភ្នាក់ងារ សហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍ អន្តរជាតិ USAID និង អង្គការ ILO ***គំរោងរោងចក្រកាត់ដេរប្រសើរ នៅកម្ពុជា។ គំរោងរោងចក្រកាត់ដេរប្រសើរនៅកម្ពុជា*** ត្រូវបានឧបត្ថម្ភថវិកាដោយ:

អ្នកផ្តល់ជំនួយ

- រាជរដ្ឋាភិបាលកម្ពុជា
- ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ
- សហភាពសហព័ន្ធសហជីពជាតិកម្ពុជា
- សហភាពការងារកម្ពុជា
- ធនាគារពិភពលោក
- ក្រុមនៃអ្នកបញ្ជាទិញអន្តរជាតិ

សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង:

***រោងចក្រកាត់ដេរប្រសើរនៅកម្ពុជា***

**អង្គការពលកម្មអន្តរជាតិ**

លេខ៥ ផ្លូវលេខ៣២២ បឹងកេងកង១

ភ្នំពេញ កម្ពុជា

ប្រអប់សំបុត្រលេខ ២៦៤២

ទូរស័ព្ទ : (+៨៥៥) ២៣ ២១២ ៨៤៧

(+៨៥៥) ២៣ ២២០ ៣៦២

ទូរសារ : (+៨៥៥) ២៣ ២១២ ៩០៣

អ៊ីម៉ែល : betterfactories@ilo.org

វ៉ិបសាយ: www.betterfactories.org/ilo

# សារសំខាន់ៗដកស្រង់ពីឈុតនេះ

- អ្នកមានសិទ្ធិឈប់សំរាលកូន
- ជាជំរើសដ៏ល្អបំផុត ដែលម្តាយគ្រប់រូបបន្តបំបៅដោះកូនអោយបានយ៉ាងហោចណាស់ រយៈពេល ៦ខែ
- កុំបំបៅទឹកដោះគោហ្វរមីឡា ជំនួសទឹកដោះម្តាយ
- ច្បាប់ចែងថា អ្នកអាចបំបៅដោះកូននៅក្នុងម៉ោងធ្វើការបាន